ASIAN DEVELOPMENT BANK
LAW AND POLICY REFORM PROGRAM

# សិក្ខាសាលា<br>ស្តីពី<br>ការ**បង្កើត** និងដំណើរការតុលាការពាណិជ្ជកម្មកម្ពុជា

**ថ្ងៃអង្គារ៍ ទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២**
**បន្ទប់ Royal Ballroom សណ្ឋាគារ Raffles  Le Royal ភ្នំពេញ កម្ពុជា**

របៀបវារៈ

| | |
|---|---|
| | **កម្មវិធីបើក** |
| **8:30 – 8:45** | **គោរពភ្លេងជាតិ**<br>**មតិចំណាប់អារម្មណ៍**<br>***លោកស្រី Jyotsana Varma***, *នាយិកាធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ប្រចាំប្រទេសកម្ពុជា (៥នាទី)*<br>**មតិស្វាគមន៍និងសុន្ទរកថាបើកសិក្ខាសាលា**<br>***ឯឧ. ជីវ សុងហាក់*** *រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌កម្ពុជា (៥នាទី)* |
| | **វគ្គសិក្ខាសាលា** |
| **8:45 – 10:15** | **វគ្គទី១៖បញ្ហាប្រឈម និងដំណោះស្រាយក្នុងការបង្កើតតុលាការពាណិជ្ជកម្មប្រកបដោយប្រសិទ្ធភាព**<br>***អ្នកសម្របសម្រួល: លោកស្រី Fiona Connell***, *ប្រធានក្រុមផ្នែកច្បាប់ពាណិជ្ជកម្ម កម្មវិធីកសាងសមត្ថភាពតុលាការ, ADB (ទីប្រឹក្សា)*<br>• ***ឯឧ. ម៉ុង មុនីចរិយា*** *ប្រធានសាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ* “តុលាការនៅក្នុងប្រទេសកម្ពុជា និងបញ្ហាប្រឈម និងដំណោះស្រាយក្នុងការរៀបចំតុលាការជំនាញផ្នែកពាណិជ្ជកម្មនៅកម្ពុជា”<br>• ***ចៅក្រម Gaetano (Tony) Pagone***, ចៅក្រមតុលាការពាណិជ្ជកម្ម (ចូលនិវត្តន៍), តុលាការសហព័ន្ធអូស្ត្រាលី *“បទពិសោធន៍ស្តីពីការបង្កើតតុលាការពាណិជ្ជកម្មនៅអូស្ត្រាលី ”*<br>• ***ចៅក្រម Bernard Rix***, ចៅក្រមតុលាការពាណិជ្ជកម្ម (ចូលនិវត្តន៍), តុលាការពាណិជ្ជកម្ម និងនាវាកិច្ចនៃប្រទេសអង់គ្លេស និងវ៉េលស៍ - *“បទពិសោធន៍ក្នុងការគ្រប់គ្រងសំណុំរឿងនៅតុលាការពាណិជ្ជកម្ម”* |
| ***10:15 – 10:40*** | ***សម្រាក និងថតរូប*** |
| **10:40 – 11:30** | **វគ្គទី២៖ ការអនុវត្តនៅតុលាការពាណិជ្ជកម្ម៖** ចំណុចរួមនិងចំណុចខុសគ្នា នៃការបង្កើតតុលាការពាណិជ្ជកម្ម<br>*អ្នកសម្របសម្រួល៖ ចៅក្រម Tom Crabtree,* វិទ្យាស្ថានជាតិផ្នែកតុលាការ នៃប្រទេសកាណាដា<br>• ចំណាប់អារម្មណ៍៖ *ចៅក្រម Tom Crabtree,* ប្រធានមន្ត្រីតុលាការ នៃ វិទ្យាស្ថានតុលាការជាតិនៃប្រទេសកាណាដា |

| | |
|---|---|
| | • *ចៅក្រម Ulrike Willoughby*, ប្រធានសាលាឧទ្ធរណ៍ Frankfurt/Main, ប្រទេសអាល្លឺម៉ង់ –ការអនុវត្តនៅតុលាការពាណិជ្ជកម្ម៖ ចំណុចរួមនិងចំណុចខុសគ្នា<br>• *លោក Christopher Campbell-Holt*, មន្ត្រីកាន់កាប់បញ្ជីនៃតុលាការ Astana IFC - *តើត្រូវចាប់ផ្តើមពីដំបូងដោយរបៀបណា៖ លំដាប់លំដោយនៃការរៀបចំតុលាការពាណិជ្ជកម្មថ្មីមួយ និងការដាក់ឱ្យដំណើរការតុលាការនេះនៅដំណាក់កាលដំបូង* |
| **11:30 – 12:00** | **វគ្គពិភាក្សា** |
| ***12:00 – 1:15*** | ***សម្រាកអាហារថ្ងៃត្រង់ (ភោជនីយដ្ឋាន Le Phnom 1929)***<br>*(ទទួលដោយ ADB)* |
| ***1:15 – 2:00*** | **វគ្គទី៣៖ គំរូនៃតុលាការពាណិជ្ជកម្ម និងមូលដ្ឋានគ្រឹះនៃបច្ចេកវិទ្យាតុលាការ**<br>**អ្នកសម្របសម្រួល៖**<br>***លោក Ljubomir Petruljeskov***, អ្នកជំនាញផ្នែកអភិវឌ្ឍតុលាការ<br>• ***លោក Ljubomir Petruljeskov***, អ្នកជំនាញផ្នែកអភិវឌ្ឍតុលាការ - *បទពិសោធន៍ និងមេរៀនដែលបានរៀនសូត្រក្នុងការអភិវឌ្ឍតុលាការនៅអឺរ៉ុប*<br>• ***បណ្ឌិត Mary Mitsi***, នាយកផ្នែកអប់រំប្រតិបត្តិ, មជ្ឈមណ្ឌលសម្រាប់ការសិក្សាច្បាប់ពាណិជ្ជកម្ម នៃសាកលវិទ្យាល័យ Queen Mary University London *(ចូលរួមពីចម្ងាយ)* - *បទបង្ហាញអំពីគំរូនៃតុលាការពាណិជ្ជកម្ម*<br>• ***លោក Simone Ginzburg***, អ្នកជំនាញផ្នែករៀបចំផែនការ និងការអនុវត្តវិស័យយុត្តិធម៌តាមប្រព័ន្ធអេឡិចត្រូនិក *(ចូលរួមពីចម្ងាយ)* - *ការរៀបចំលំដាប់លំដោយ IT នៅក្នុងតុលាការពាណិជ្ជកម្ម* |
| **2:00 - 2:20** | **វគ្គសំណួរ&ចម្លើយ ពេញអង្គ** |
| **2:20 – 2:30** | **វគ្គបូកសរុប៖ ចំណាប់អារម្មណ៍ និងអនុសាសន៍**<br>• **លោកស្រី Christina Pak** ប្រធានក្រុមមេធាវី និងជាប្រធានក្រុមការងារសម្រាប់កំណែទម្រង់ច្បាប់ និងគោលនយោបាយ នៃ ADB ៖ ជំនួយបច្ចេកទេសតំបន់របស់ ADB លើការពង្រឹងសមត្ថភាពតុលាការឆ្ពោះទៅរកការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព នៅអាស៊ី និងប៉ាស៊ីហ្វិក<br>• **ឯឧ. ជីវ សុងហាក់** រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌កម្ពុជា |

## *វគ្គពិភាក្សាស៊ីជម្រៅជាមួយគណៈកម្មាធិការរៀបចំតុលាការពាណិជ្ជកម្ម*
## *(វគ្គចង្អៀតក្រុមតូច សម្រាប់តែមន្ត្រី MOJ ដែលត្រូវបានអញ្ជើញប៉ុណ្ណោះ)*

**3:00 – 4:00**

**កិច្ចពិភាក្សាក្រុមតូច វគ្គទី១៖ រចនាសម្ព័ន្ធ យុត្តាធិការ និងការរៀបចំនៃតុលាការពាណិជ្ជកម្ម**

***អ្នកសម្របសម្រួល៖ ចៅក្រម Tom Crabtree,***
*វិទ្យាស្ថានតុលាការជាតិនៃប្រទេសកាណាដា*

***ចំណាប់អារម្មណ៍បើកកម្មវិធី ពីប្រធានគណៈកម្មាធិការនៃក្រសួងយុត្តិធម៌ (៥នាទី)***

*MOJ ត្រូវបានស្នើឱ្យដាក់ជូននូវសំនួរ និងប្រធានបទពិភាក្សា មុនពេលកិច្ចប្រជុំ និងត្រូវបានស្វាគមន៍យ៉ាងកក់ក្តៅ ឱ្យលើកឡើងនូវសំនួរបន្ថែមក្នុងអំឡុងពេលនៃកិច្ចពិភាក្សាក្រុមតូច*

***អ្នកចូលរួម៖***
- *តំណាងមកពីគណៈកម្មាធិការរៀបចំទូទៅរបស់ MOJ សម្រាប់រៀបចំ និងបង្កើតតុលាការឯកទេសពាណិជ្ជកម្ម*
- *តំណាងមកពីគណៈកម្មាធិការរបស់ MOJ ដែលរៀបចំសេចក្តីព្រាងវិធាននៃនីតិវិធីសម្រាប់តុលាការឯកទេសពាណិជ្ជកម្ម*
- *ជំនាញការអន្តរជាតិ*
- *ក្រុមការងារ ADB*

***4:00 – 4:15*** — ***សម្រាក***

**4:15 – 5:15**

**កិច្ចពិភាក្សាក្រុមតូច វគ្គទី២៖ នីតិវិធីនៅក្នុងតុលាការពាណិជ្ជកម្ម - ប្រសិទ្ធផល និងភាពយុត្តិធម៌**

***អ្នកសម្របសម្រួល៖ ចៅក្រម Tom Crabtree,***
*វិទ្យាស្ថានតុលាការជាតិនៃប្រទេសកាណាដា*

***ចំណាប់អារម្មណ៍បើកកម្មវិធី ពីប្រធានគណៈកម្មាធិការនៃក្រសួងយុត្តិធម៌ (៥នាទី)***

*MOJ ត្រូវបានស្នើឱ្យដាក់ជូននូវសំនួរ និងប្រធានបទពិភាក្សា មុនពេលកិច្ចប្រជុំ និងត្រូវបានស្វាគមន៍យ៉ាងកក់ក្តៅ ឱ្យលើកឡើងនូវសំនួរបន្ថែមក្នុងអំឡុងពេលនៃកិច្ចពិភាក្សាក្រុមតូច*

***អ្នកចូលរួម៖***
- *តំណាងមកពីគណៈកម្មាធិការរៀបចំទូទៅរបស់ MOJ សម្រាប់រៀបចំ និងបង្កើតតុលាការឯកទេសពាណិជ្ជកម្ម*
- *តំណាងមកពីគណៈកម្មាធិការរបស់ MOJ ដែលរៀបចំសេចក្តីព្រាងវិធាននៃនីតិវិធីសម្រាប់តុលាការឯកទេសពាណិជ្ជកម្ម*
- *ជំនាញការអន្តរជាតិ*
- *ក្រុមការងារ ADB*

| | | |
|---|---|---|
| **5:15 – 5:25** | **វគ្គបញ្ចប់៖ ចំណាប់អារម្មណ៍ និងអនុសាសន៍**<br><br>• ***លោកស្រី Christina Pak*** ប្រធានក្រុមមេធាវី និងជាប្រធានក្រុមការងារសម្រាប់កំណែទម្រង់ច្បាប់ និងគោលនយោបាយ នៃ ADB ៖ ជំនួយបច្ចេកទេសតំបន់របស់ ADB លើការពង្រឹងសមត្ថភាពតុលាការឆ្ពោះទៅរកការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព នៅអាស៊ី និងប៉ាស៊ីហ្វិក<br>• ***ឯឧ. ជីវ សុងហាក់*** រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌កម្ពុជា | |
| | ចប់សិក្ខាសាលា | |

# វាគ្មិននៅក្នុងសិក្ខាសាលា



**Christopher Campbell-Holt**
*មន្ត្រីកាន់កាប់បញ្ជី, នាយកប្រតិបត្តិ*
*តុលាការមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិ Astana (AIFC)*

លោក Campbell-Holt គឺជាមន្ត្រីកាន់កាប់បញ្ជី និងជានាយកប្រតិបត្តិនៃតុលាការ AIFC។ គាត់ក៏ជាចៅក្រមអនុវត្តច្បាប់នៃតុលាការ AIFC ផងដែរ។ គាត់ទទួលខុសត្រូវលើការគ្រប់គ្រង និងរដ្ឋបាលតុលាការប្រចាំថ្ងៃ និងការគ្រប់គ្រងសំណុំរឿងបណ្តឹងវិវាទនៅចំពោះមុខតុលាការ ទៅតាមកម្រិតដែលបានធ្វើប្រតិភូកម្ម ឬបង្គាប់បញ្ជាដោយប្រធានអង្គចៅក្រម។ ក្នុងនាមជាចៅក្រមអនុវត្តច្បាប់ គាត់ទទួលខុសត្រូវចេញដីកាអនុវត្តច្បាប់ស្របតាមសាលក្រម និងដីការបស់តុលាការ។

គាត់បានគ្រប់គ្រងការបង្កើតតុលាការ AIFC និង IAC ចាប់តាំងពីពេលមានគំនិតចាប់ផ្តើមដំបូងរហូតដល់ក្លាយជាស្ថាប័នដោះស្រាយវិវាទអន្តរជាតិឯករាជ្យជាចម្បង ដែលមានការទទួលស្គាល់នៅអឺរ៉ាស៊ី។ គាត់គឺជាសមាជិកនៃក្រុមប្រឹក្សាប្រឹក្សាច្បាប់ AIFC ដែលត្រួតពិនិត្យ និងអនុម័តច្បាប់ AIFC ដែលយកគំរូតាម common law។ គាត់គឺជាសមាជិកនៃក្រុមប្រឹក្សាតុលាការកំពូលអន្តរជាតិនៃសាធារណរដ្ឋកាហ្សាក់ស្ថាន ដែលផ្តល់ប្រឹក្សាលើកំណែទម្រង់តុលាការកាហ្សាក់ស្ថាន និងការដោះស្រាយវិវាទ។

គាត់មានបទពិសោធន៍ផ្នែកច្បាប់អន្តរជាតិរយៈពេល ២០ឆ្នាំ ដែលទទួលបាននៅខណៈពេលរស់នៅ និងធ្វើការនៅចក្រភពអង់គ្លេស សហរដ្ឋអាមេរិក មជ្ឈិមបូព៌ា និងអាស៊ីកណ្តាល។ គាត់គឺជាមន្ត្រីអគ្រានុកូលដ្ឋាននៅតុលាការពាណិជ្ជកម្មនៃមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិ និងមជ្ឈមណ្ឌលដោះស្រាយវិវាទជំនួសនៅប្រទេសកាតា និងបានផ្តល់ប្រឹក្សាដល់រដ្ឋាភិបាល និងអង្គការជាច្រើនអំពី common law និងការអភិវឌ្ឍស្ថាប័នដោះស្រាយវិវាទ រួមទាំងនៅមជ្ឈិមបូព៌ា អាស៊ីកណ្តាល អឺរ៉ុបខាងកើត និងអាមេរិកខាងត្បូងផងដែរ។



**Fiona Connell**
*ទីប្រឹក្សា និងជាប្រធានក្រុម*
*កម្មវិធីកសាងសមត្ថភាពតុលាការពាណិជ្ជកម្ម*
*ធនាគារអភិវឌ្ឍន៍អាស៊ី*

Fiona Connell បានអនុវត្តច្បាប់នៅអាស៊ីអស់រយៈពេលជាង២៥ឆ្នាំ និងមានបទពិសោធន៍ច្រើន ទាំងក្នុងប្រតិបត្តិការពាណិជ្ជកម្ម និងប្រតិបត្តិការរដ្ឋនៅក្នុងប្រទេសជាសមាជិកជាច្រើនរបស់ ADB។ អាជីពដំបូងរបស់លោកស្រីនៅក្នុងវិស័យឯកជនបាន ផ្តោតលើបំណុលរួម (syndicated debt) ហិរញ្ញប្បទានគម្រោង និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដោយផ្តោតចម្បងលើហេដ្ឋារចនាសម្ព័ន្ធថាមពល ហើយគាត់ក៏បានធ្វើការងារលើការវិនិយោគដោយផ្ទាល់ពីបរទេស និងប្រតិបត្តិការពាណិជ្ជកម្ម និងប្រតិបត្តិការសារជីវកម្មដទៃទៀត។ ក្រោយពេលចូលរួមនៅក្នុងនាយកដ្ឋានច្បាប់របស់ ADB នៅក្នុងឆ្នាំ២០១០ លោកស្រី Fiona បានអនុវត្តការងារទាំងនៅក្នុងសាខាផ្នែកវិស័យរដ្ឋ និងឯកជនរបស់ធនាគារនេះ។ គាត់ក៏បានចូលរួមនៅក្នុងការងារកំណែទម្រង់ច្បាប់ និងគោលនយោបាយរបស់ ADB ផងដែរ ជាពិសេសក្រោយពេលដែលគាត់បានចូលរួមជាមួយនិវាសដ្ឋានបេសកកម្មប្រចាំប្រទេសចិន ក្នុងឆ្នាំ២០១៣។ គាត់បានធ្វើការងារជាមួយទីភ្នាក់ងាររដ្ឋាភិបាលចិន រួមទាំងតុលាការកំពូល ស្តីពីការកែលម្អច្បាប់ និងការអភិវឌ្ឍសមត្ថភាពនៅក្នុងលិខិតបទដ្ឋានគតិយុត្តផ្នែកហិរញ្ញវត្ថុ , PPP , យុត្តិសាស្ត្របរិស្ថាន និងការប្រើប្រាស់បច្ចេកវិទ្យាដោយតុលាការ។ លោកស្រី Fiona

ក៏ជាសន្ទានការី និងមជ្ឈត្តករផងដែរ។ បច្ចុប្បន្ន គាត់គឺជាប្រធានផ្នែកច្បាប់ពាណិជ្ជកម្មនៃកម្មវិធីជំនួយបច្ចេកទេសតំបន់របស់ ADB៖ ការពង្រឹងសមត្ថភាពតុលាការឆ្ពោះទៅរកការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាពនៅអាស៊ី និងប៉ាស៊ីហ្វិក។



**ចៅក្រម Tom Crabtree**
*ប្រធានមន្ត្រីតុលាការ*
*វិទ្យាស្ថានតុលាការជាតិ*
*ប្រទេសកាណាដា*

ក្នុងនាមជាគណៈវិនិច្ឆ័យប្រកបដោយជំនាញខ្ពស់ និងជាអ្នកគាំទ្រដ៏ខ្លាំងក្លាចំពោះការអភិវឌ្ឍវិជ្ជាជីវៈតុលាការ លោកចៅក្រម Crabtree បានចូលរួម NJI ក្នុងនាមជាប្រធានមន្ត្រីតុលាការ ក្រោយពីបានបម្រើការងារនៅក្នុងក្រុមប្រឹក្សាភិបាល ជាអ្នកតំណាងក្រុមប្រឹក្សាប្រធានអង្គចៅក្រមនៃប្រទេសកាណាណា។ គាត់មានអាជីពគួរឱ្យកត់សម្គាល់នៅក្នុងអង្គចៅក្រម។ គាត់ត្រូវបានតែងតាំងដំបូងឱ្យបម្រើការងារនៅឯតុលាការខេត្តនៃ British Columbia ក្នុងឆ្នាំ១៩៩៩ និងបានក្លាយជាប្រធានចៅក្រមក្នុងឆ្នាំ២០១០។ គាត់ត្រូវបានតែងតាំងឱ្យបម្រើការងារនៅឯតុលាការកំពូលនៃ British Columbia ក្នុងឆ្នាំ២០១៨។ នៅក្នុងអាជីពរបស់លោក ចៅក្រម Crabtree បានបង្ហាញឱ្យឃើញនូវចំណាប់អារម្មណ៍លើបញ្ហាជនជាតិដើមភាគតិច។ ខណៈពេលដែល ប្រធានចៅក្រមបម្រើការងារនៅ B.C. គាត់បានធ្វើការងារជាមួយសហគមន៍ជនជាតិដើមភាគតិច ដើម្បីអភិវឌ្ឍតុលាការកាត់ទោសថ្មីសម្រាប់ជនជាតិដើមភាគតិច ចំនួន៥ និងអភិក្រមថ្មីមួយ ដើម្បីដោះស្រាយករណីពាក់ព័ន្ធកុមារជនជាតិដើមភាគតិចដែលកំពុងស្ថិតក្រោមការថែទាំ។ គាត់ក៏បានត្រួសត្រាយនូវការប្រើប្រាស់បច្ចេកវិទ្យាដោយមិនត្រឹមតែធ្វើឱ្យការងារនៅឯតុលាការរបស់លោកកាន់តែមានតម្លាភាព បង្គួលក្ខណៈងាយស្រួល និងមានប្រសិទ្ធភាពខ្ពស់ប៉ុណ្ណោះទេ ប៉ុន្តែក៏មានការចូលរួមជាមួយសាធារណជនផងដែរ។ ចៅក្រម Crabtree បានរួមចំណែកចំពោះការផ្តួចផ្តើមជាច្រើនពាក់ព័ន្ធនឹងការអប់រំតុលាការនៅប្រទេសកាណាដា និងនៅក្រៅប្រទេស។ គាត់ក៏មានភាពសកម្មផងដែរនៅក្នុងគណៈកម្មាធិការអប់រំតុលាការ ក្នុងនាមជាសមាជិកនៃគណៈកម្មាធិការរៀបចំផែនការតុលាការ សម្រាប់កម្មវិធីជាតិជាច្រើនរបស់ NJI និងបានផ្តល់តម្លៃដល់សមាជិកមហាវិទ្យាល័យ។



**Simone Ginzburg**
*ទីប្រឹក្សាឯករាជ្យ*
*យុត្តិធម៌តាមប្រព័ន្ធអេឡិចត្រូនិក*

Simone Ginzburg គឺជាទីប្រឹក្សាឯករាជ្យជនជាតិអ៊ីតាលីលើយុត្តិធ៌មតាមប្រព័ន្ធអេឡិចត្រូនិក និងការកែលម្អវិស័យយុត្តិធម៌ ដែលមានមូលដ្ឋាននៅ Sarajevo Bosnia និង Herzegovina (BiH)។ ចាប់តាំងពីឆ្នាំ១៩៩៨ គាត់បានធ្វើការនៅក្នុងគម្រោងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងជំនួយ។ នៅចន្លោះឆ្នាំ២០០៥ និង ២០១១ គាត់បានបង្កើត និងដឹកនាំការអភិវឌ្ឍ និងការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធព័ត៌មានស្មុគស្មាញចំនួនពីរនៅក្នុងវិស័យយុត្តិធម៌ BiH ជាបន្តបន្ទាប់ ដែលប្រព័ន្ធទាំងពីរនេះនៅតែដំណើរការនាពេលបច្ចុប្បន្ន។ ចាប់តាំងពីឆ្នាំ២០១៣ មក លោកបានចូលបម្រើការងារជាអ្នកជំនាញ និងទីប្រឹក្សាឯករាជ្យសម្រាប់អង្គការអន្តរជាតិខុសៗគ្នា រួមមាន សហភាពអឺរ៉ុប ក្រុមប្រឹក្សាអឺរ៉ុប និងគណៈកម្មការប្រសិទ្ធភាព និងគុណភាពយុត្តិធម៌ (CEPEJ)

និងគម្រោងម្ចាស់ជំនួយទ្វេភាគីជាច្រើនទៀត សំដៅកែលម្អប្រសិទ្ធភាព និងគុណភាពយុត្តិធម៌នៅ ប្រទេស Azerbaijan, Bosnia និង Herzegovina, Bulgaria, Croatia, Georgia, Kosovo, Malawi, Malta, Montenegro, Morocco, Romania, Serbia, Uganda និង Ukraine។ គាត់គឺជាផ្នែកមួយនៃក្រុមអ្នកជំនាញផ្នែកយុត្តិធម៌តាមប្រព័ន្ធអ៊ីនធឺណិតនៃ CEPEJ។



**Jesse Mark**
*មេធាវីផ្នែកអប់រំឌីជីថល*
*វិទ្យាស្ថានតុលាការជាតិកាណាដា (NJI)*

Jesse គឺជាទីប្រឹក្សាផ្នែកអប់រំឌីជីថលនៅវិទ្យាស្ថានជាតិយុត្តិធម៌ (NJI) នៃប្រទេសកាណាដា ដែលនៅទីនោះ គាត់មានភារកិច្ចផលិតបទពិសោធន៍សិក្សាតាមអ៊ីនធឺណិតប្រកបដោយនវានុវត្តន៍ សម្រាប់ចៅក្រម ដោយផ្តោតលើបញ្ហាដែលប៉ះពាល់ដល់ប្រជាជនងាយរងគ្រោះ។ Jesse មានប្រវត្តិសិក្សាទាំងផ្នែកអប់រំ និងប្រព័ន្ធព័ត៌មាន។ មុនពេលចូលរួមជាមួយ NJI Jesse បានធ្វើការនៅគ្លីនិកអប់រំច្បាប់សាធារណៈរបស់ Legal Aid Ontario ដើម្បីបង្កើតផលិតផលឌីជីថលជាភាសាសាមញ្ញ ដែលជួយប្រជាជនឱ្យយល់ និងអនុវត្តសិទ្ធិតាមផ្លូវច្បាប់របស់ពួកគេ។ នៅខាងក្រៅពិភពនៃការអប់រំតាមប្រព័ន្ធឌីជីថល និងអ៊ីនធឺណិត Jesse ក៏បានធ្វើផែនការ និងផ្តល់សិក្ខាសាលាស្តីពីសិទ្ធិតាមផ្លូវច្បាប់ និងគរុកោសល្យរាប់មិនអស់ដល់អ្នកអនុវត្តច្បាប់ និងមិនអនុវត្តច្បាប់។ នៅពេលចាប់ផ្តើមអាជីពផ្នែកច្បាប់ដំបូងៗ Jesse គឺជាអ្នកការពារក្តីសាកល្បងសម្រាប់អង្គការតស៊ូមតិយុវជនឈានមុខគេមួយនៃប្រទេសកាណាដា។ គាត់បានដឹកនាំសំណុំរឿងដែលនឹងត្រូវប្រើជាគំរូនៅពេលក្រោយជាច្រើនសំណុំរឿងបានដោយជោគជ័យ ដែលបានកែប្រែទិដ្ឋភាពសំខាន់ៗនៃច្បាប់យុវជន។



**Mary Mitsi**
*នាយិកា នៃការអប់រំប្រតិបត្តិ*
*មជ្ឈមណ្ឌលសម្រាប់ការសិក្សាច្បាប់ពាណិជ្ជកម្ម (CCLS)*

Mary គឺជាសាស្ត្រាចារ្យផ្នែកច្បាប់ពាណិជ្ជកម្ម ឯកទេសផ្នែកមជ្ឈត្តការអន្តរជាតិ។ លោកស្រីបង្រៀននៅក្នុងកម្មវិធី LLM នៅទីក្រុងឡុងដ៍ និងប៉ារីស និងជាពិសេសវគ្គសិក្សាអំពី "ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ" "ជម្លោះនៃច្បាប់" និង "មជ្ឈត្តការពាណិជ្ជកម្ម" "មជ្ឈត្តការលើការវិនិយោគអន្តរជាតិ" "ច្បាប់និងអភិបាលកិច្ចឆ្លងដែន" "ច្បាប់របស់សហភាពអឺរ៉ុប"។ ការបោះពុម្ពផ្សាយរបស់ Mary រួមមានម៉ូណូក្រាហ្វស្តីពី "ដំណើរការធ្វើសេចក្តីសម្រេចរបស់តុលាការមជ្ឈត្តការរវាងវិនិយោគិន-រដ្ឋ" (Kluwer Law International ឆ្នាំ២០១៩) និងអត្ថបទ "សហព័ន្ធអឺរ៉ុបសម្រាប់ច្បាប់វិនិយោគនិងមជ្ឈត្តការ (EFILA) ការឆ្លើយតបទៅនឹងការរិះគន់ប្រឆាំងនឹង ISDS" (Mary Mitsi at als JOIA (ទិន្នានុប្បវត្តិអំពីមជ្ឈត្តការអន្តរជាតិ) - (២០១៦) ៣៣ J. Int. Arb. ១)។ លោកស្រីក៏បានធ្វើការជាជំនួយការគម្រោងសម្រាប់ក្រុមការងារចម្រុះ QM-ICCA លើការផ្តល់មូលនិធិដល់ តតិយជនផងដែរ។

Mary គឺជានាយកផ្នែកអប់រំប្រតិបត្តិនៅ CCLS ដែលរួមចំណែកដល់ការបណ្តុះបណ្តាលអ្នកជំនាញផ្នែកឧស្សាហកម្ម។ លោកស្រីផ្តល់កម្មវិធីបណ្តុះបណ្តាលដល់អ្នកអនុវត្ត មន្ត្រីរដ្ឋាភិបាល និងតុលាការ។ លោកស្រីក៏បានដឹកនាំ និងធ្វើការនៅក្នុងគម្រោងនានារបស់ធនាគារអឺរ៉ុបសម្រាប់ការកសាងឡើងវិញ និងការអភិវឌ្ឍ និងស្ថាប័នអន្តរជាតិដទៃទៀត។

Mary មានបទពិសោធន៍ក្នុងការអនុវត្តមជ្ឈត្តការនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល និង common law និងបានធ្វើការលើសំណុំរឿង មជ្ឈត្តការអន្តរជាតិ (LCIA, ICC, HKIAC, ICSID)។ លោកស្រីបានទទួលការអនុញ្ញាតឱ្យធ្វើជាមេធាវី (គណៈមេធាវី Thessaloniki) ហើយលោកស្រីក៏បានបម្រើការងារជាទីប្រឹក្សាច្បាប់ពិសេសនៅក្រសួងអភិវឌ្ឍន៍នៃប្រទេសក្រិច នាពេលកន្លងមក ដែលផ្តល់ប្រឹក្សាលើបញ្ហាទាក់ទងនឹងច្បាប់ប្រកួតប្រជែង និងសហគ្រិនភាព។



**Hon. Gaetano Tony Pagone**
*ចៅក្រម*
*អតីតចៅក្រមនៃតុលាការកំពូល ទីក្រុងវិចតូរីយ៉ា និង តុលាការសហព័ន្ធអូស្ត្រាលី*

The Hon. G Tony Pagone អនុវត្តការងារផ្នែកមជ្ឈត្តការ សន្ទានកម្ម និងទីប្រឹក្សា។ ការិយាល័យរបស់គាត់មានទីតាំងស្ថិតនៅជាន់ទី ១៨ នៃ Owen Dixon Chambers West។ គាត់បានចូលនិវត្តន៍ពីតុលាការសហព័ន្ធអូស្ត្រាលី ដែលគាត់ធ្លាប់ជាចៅក្រមសម្របសម្រួលថ្នាក់ជាតិនៃតំបន់អនុវត្តពន្ធដារថ្នាក់ជាតិ។ មុនពេលទទួលការតែងតាំងនៅតុលាការសហព័ន្ធ គាត់គឺជាចៅក្រមជំនុំជម្រះក្តីនៃតុលាការកំពូល Victoria និងធ្លាប់ជាចៅក្រមទទួលបន្ទុកតុលាការពាណិជ្ជកម្មនៃតុលាការនោះ។

គាត់បានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ Monash ក្នុងឆ្នាំ១៩៧៩ ថ្នាក់បរិញ្ញាបត្រច្បាប់ និងពីសាកលវិទ្យាល័យ Cambridge ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកច្បាប់ នៅឆ្នាំ១៩៨៣។ នៅឆ្នាំ២០១៤ គាត់បានទទួលរង្វាន់ LLD ពីសាកលវិទ្យាល័យ Melbourne សម្រាប់ការស្រាវជ្រាវរបស់គាត់ និងបានបោះពុម្ពផ្សាយការងារស្តីពីបញ្ញត្តិប្រឆាំងនឹងការគេចខ្លួន។ គាត់ទទួលបានការទទួលស្គាល់នៅក្នុងរដ្ឋ Victoria ក្នុងនាមជាអ្នកអនុវត្តច្បាប់នៅឆ្នាំ១៩៨០ បានចុះហត្ថលេខាលើកំណត់ត្រាការការពារក្តី នៅឆ្នាំ១៩៨៥ និងត្រូវបានតែងតាំងជាទីប្រឹក្សារបស់ព្រះមហាក្សត្រិយានី Victoria នៅឆ្នាំ១៩៩៦។ គាត់បានបំពេញការងារយ៉ាងទូលំទូលាយនៅក្នុងច្បាប់ពន្ធដារ ច្បាប់ពាណិជ្ជកម្ម

ច្បាប់រដ្ឋបាល ច្បាប់រដ្ឋធម្មនុញ្ញ ច្បាប់សាធារណៈ និងច្បាប់ស្តីពីសិទ្ធិមនុស្សក្នុងអំឡុងពេលដែលគាត់បំពេញការងារនៅគណៈមេធាវី។ គាត់ក៏ជាទីប្រឹក្សាពិសេសរបស់ការិយាល័យពន្ធដារអូស្ត្រាលី នៅចន្លោះឆ្នាំ២០០២ និងឆ្នាំ២០០៤ ផងដែរ។ គាត់គឺជាសាស្ត្រាចារ្យនៃសាលាច្បាប់ Melbourne និងបានបង្រៀនវគ្គសិក្សាថ្នាក់ក្រោយឧត្តមសិក្សាជាច្រើននៅសាលាច្បាប់ Melbourne និងម្តងម្កាល នៅមហាវិទ្យាល័យច្បាប់នៃសាកលវិទ្យាល័យ Monash។ គាត់គឺជាប្រធានសមាគមចៅក្រមអន្តរជាតិ និងធ្លាប់ជាប្រធានសមាគមចៅក្រមពន្ធដារអន្តរជាតិ។



**Christina Pak**
*ប្រធានក្រុមមេធាវី និងប្រធានក្រុមការងារ*
*កម្មវិធីកំណែទម្រង់ច្បាប់ និងគោលនយោបាយ*
*ធនាគារអភិវឌ្ឍន៍អាស៊ី*

Christina មានឯកទេសនៅក្នុងវិស័យហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍអន្តរជាតិ កំណែទម្រង់ច្បាប់ និងគោលនយោបាយ ការដោះស្រាយវិវាទ និងស្តង់ដា ESG ព្រមទាំងធ្វើការដឹកនាំលើបញ្ហាអភិវឌ្ឍប្រកបដោយចិរភាព។ បច្ចុប្បន្ន គាត់គឺជាប្រធានក្រុមមេធាវី នៃធនាគារអភិវឌ្ឍអាស៊ី និងគ្រប់គ្រងកម្មវិធីកំណែទម្រង់ច្បាប់ និងគោលនយោបាយ នៃការិយាល័យអគ្គមេធាវី ដោយរៀបចំ និងអនុវត្តគម្រោងជំនួយបច្ចេកទេសសម្រាប់កំណែទម្រង់ច្បាប់ និងតុលាការទូទាំងតំបន់អាស៊ី និងប៉ាស៊ីហ្វិក។ Christina ឃ្លាំមើលទៅលើគម្រោងផ្សេងៗគ្នានៅក្នុងវិស័យកិច្ចការពារបរិស្ថាន និងការប្រែប្រួលអាកាសធាតុ សមភាពយេនឌ័រ ការអភិវឌ្ឍន៍វិស័យឯកជន ភាពជាដៃគូរវាងរដ្ឋ និងឯកជន និងសេដ្ឋកិច្ចឌីជីថល។ គាត់ក៏បម្រើការងារជាអ្នកផ្តល់ប្រឹក្សាគោលនយោបាយនៃយន្តការគណនេយ្យភាពរបស់ ADB ដែលផ្តល់យោបល់ដល់ក្រុមប្រឹក្សានាយក ការិយាល័យគណៈកម្មការត្រួតពិនិត្យភាពអនុលោម និងការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស។ នៅក្នុងតួនាទីកន្លងមករបស់គាត់ក្នុងនាមជាអ្នកផ្តល់ប្រឹក្សាគម្រោងមួយរូបនៅឯ ADB Christina បានធ្វើការងារលើគម្រោងពហុវិស័យដ៏ស្មុគស្មាញនៅតំបន់អាស៊ីកណ្តាល អាស៊ីអាគ្នេយ៍ និងអាស៊ីប៉ូព៉ា។ មុនពេលចូលរួមជាមួយ ADB, Christina គឺជាអ្នកផ្តល់ប្រឹក្សាច្បាប់ និងជាអនុប្រធានសម្រាប់ ទីផ្សារ និងធនាគារអន្តរជាតិ នៅឯធនាគារចក្រភពអង់គ្លេសមួយដែលមានមូលដ្ឋាននៅប្រទេសសិង្ហបូរី និងជាមន្ត្រីហិរញ្ញវត្ថុ នៅឯក្រុមហ៊ុនច្បាប់ដ៏ធំមួយក្នុងទីក្រុងញ៉ូវយ៉ក។ បច្ចុប្បន្ន គាត់គឺជាសមាជិកគណៈកម្មាធិការដឹកនាំនៃគណៈកម្មការពិភពលោករបស់ IUCN ស្តីពីច្បាប់បរិស្ថាន និងជាសមាជិកវិទ្យាស្ថាន Chartered នៃមជ្ឈត្តករ។ Christina គឺជាមេធាវីមួយរូបដែលមានការទទួលស្គាល់គុណវុឌ្ឍិនៅរដ្ឋញ៉ូវយ៉ក និងញ៉ូវចេស៊ី សហរដ្ឋអាមេរិក។



**Ljubomir Petruljeskov**
*ជំនាញការផ្នែកអភិវឌ្ឍតុលាការ និងកសាងសមត្ថភាព (ទីប្រឹក្សា)*
*ធនាគារអភិវឌ្ឍន៍អាស៊ី*

Ljubomir Petruljeskov គឺជាអ្នកវិជ្ជាជីវៈអន្តរជាតិផ្នែកការងារអភិវឌ្ឍន៍ប្រកបដោយបទពិសោធន៍ ជាមួយនឹងសារតាសិក្សាពហុវិស័យ។ គាត់គឺជាទីប្រឹក្សារបស់ ADB ដែលបានអនុវត្តគម្រោងជំនួយបច្ចេកទេសលើការងារកំណែទម្រង់តុលាការ ច្បាប់ពាណិជ្ជកម្ម ការកសាងសមត្ថភាពសម្រាប់អ្នកវិជ្ជាជីវៈផ្នែកច្បាប់ និងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ Ljubomir

បានបម្រើការងារជាទីប្រឹក្សាលើគម្រោងនានានៅក្នុងសហភាពអឺរ៉ុប អឺរ៉ុបខាងកើត និងបណ្តាប្រទេសនៅអាស៊ីកណ្តាល។

សម្រាប់រយៈពេល២០ឆ្នាំចុងក្រោយ គាត់បាននិងកំពុងបម្រើការងារជាមួយអង្គការហិរញ្ញវត្ថុអន្តរជាតិ ក្នុងវិស័យធនាគារសម្រាប់អតិថិជនទូទៅ និងសម្រាប់អតិថិជនជាសារជីវកម្ម ច្បាប់ពាណិជ្ជកម្ម វិធីសាស្ត្របណ្តុះបណ្តាល និងភាពជាដៃគូ ព្រមទាំងការកៀរគរធនធាន។

Ljubomir Petruljeskov បានបញ្ចប់ការសិក្សាពីកម្មវិធី Weinstein JAMS International និងបានទទួលសញ្ញាបត្រថ្នាក់ MBA ពី UBI Belgium។



**Bernard Rix**
*មជ្ឈត្តករ*
*Twenty Essex*

Sir Bernard ជាមជ្ឈត្តករពេញម៉ោងនៅ Twenty Essex ដែលទទួលបានការតែងតាំងស្របតាមច្បាប់ស្ថាប័ន និងវិធាននៃការចូលកាន់តំណែងតាមស្ថានការណ៍ចំពោះមុខទាំងអស់ នៅទូទាំងពិភពលោក។ គាត់បានទទួលការតែងតាំងជាមជ្ឈត្តករ និងសន្ទានករ នៅក្នុងវិស័យជាច្រើន រួមមាន វិស័យប្រេង និងឧស្ម័ន ការដឹកជញ្ជូន ការធានារ៉ាប់រង ការលក់ទំនិញ និងប្រតិបត្តិការទិញភាគហ៊ុន។ លោកបានដើរតួជាសាក្សីជំនាញ មជ្ឈត្តករគំរូ និងប្រធានពិសេស នៅក្នុងតុលាការសហព័ន្ធនៃសហរដ្ឋអាមេរិក ព្រមទាំងជាសមាជិកតុលាការពាណិជ្ជកម្មអន្តរជាតិសិង្ហបុរី និងសាលាឧទ្ធរណ៍នៃកោះ Cayman ផងដែរ។ Sir Bernard បានចូលនិវត្តន៍នៅឆ្នាំ២០១៣ ក្នុងនាមជាចៅក្រមសាលាឧទ្ធរណ៍នៃប្រទេសអង់គ្លេស និងវែលស៍ ដោយមានបទពិសោធន៍រយៈពេល ២០ឆ្នាំ នៅតុលាការពាណិជ្ជកម្ម និងសាលាឧទ្ធរណ៍។

លើសពីនេះទៀត លោក Sir Bernard គឺជាសាស្ត្រាចារ្យនៅមជ្ឈមណ្ឌលសិក្សាច្បាប់ពាណិជ្ជកម្មនៅ Queen Mary និងជានិស្សិតកិត្តិយសនៃវិទ្យាស្ថានច្បាប់អន្តរជាតិ និងច្បាប់ប្រៀបធៀបនៃប្រទេសអង់គ្លេស។ Sir Bernard ធ្លាប់ជាប្រធានក្រុម London Philharmonic Orchestra និងបានចូលរួមក្នុងការសម្តែងរបស់ Der Rosenkavalier នៅ ENO ផងដែរ។



**Jyotsana Varma**
*នាយិកាប្រចាំប្រទេស និវាសដ្ឋានបេសកកម្មប្រចាំប្រទេសកម្ពុជា*
*ធនាគារអភិវឌ្ឍន៍អាស៊ី*

Jyotsana Varma បាន និងកំពុងបម្រើការងារនៅក្នុងវិស័យអភិវឌ្ឍអស់រយៈពេល២៩ឆ្នាំ ក្នុងនោះ១២ឆ្នាំបម្រើការងារជាមួយ ធនាគារអភិវឌ្ឍន៍អាស៊ី និង ១៧ឆ្នាំជាមួយរដ្ឋាភិបាល ដោយគ្រប់ដណ្តប់លើវិស័យការងារគោលនយោបាយអភិវឌ្ឍ ការអភិវឌ្ឍ និងការអនុវត្តគម្រោង ព្រមទាំងកិច្ចសហប្រតិបត្តិការអន្តរជាតិ។ គាត់បានចូលរួមបម្រើការងារជាមួយ ADB នៅឆ្នាំ២០០៩ នៅក្នុងលេខាធិការដ្ឋានសារជីវកម្ម និងបន្តទៅនាយកដ្ឋានអាស៊ីអាគ្នេយ៍ ដើម្បីបម្រើការងារនៅក្នុងលេខាធិការដ្ឋានមហាអនុតំបន់មេគង្គ។ ក្នុងឆ្នាំ២០០៧ គាត់បានប្តូរទៅបម្រើការងារតាមប្រទេស នៅឯប្រទេសបង់ក្លាដេស នៅក្នុងនាយកដ្ឋានអាស៊ីខាងត្បូង ដែលនៅទីនោះគាត់បានធ្វើការងារជិតស្និទ្ធជាមួយរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធដទៃទៀតអស់រយៈពេល៥ឆ្នាំ ដើម្បីអភិវឌ្ឍ

ដំណើរការការងារមួយដ៏រឹងមាំ និងប្រកបដោយពិពិធភាព ព្រមទាំងធានាឱ្យមានប្រតិបត្តិការរលូន។ មុនពេលចូលរួមបម្រើការងារជានាយិកាប្រចាំប្រទេសកម្ពុជា នៅខែកក្កដា ឆ្នាំ២០២២ គាត់បានដឹកនាំក្រុមការងារ Maldives រយៈពេលខ្លី ដោយគ្រប់គ្រងការិយាល័យសម្របសម្រួលប្រចាំប្រទេស និងសម្របសម្រួលកម្មវិធី និងគម្រោងប្រចាំប្រទេស។ មុនពេលចូលរួមបម្រើការងារជាមួយ ADB គាត់បានបម្រើការងារមុខងារសាធារណៈនៅប្រទេសឥណ្ឌាចាប់តាំងពីឆ្នាំ ១៩៩២ ដោយបានដឹកនាំក្រុមការងារធំៗកម្រិតថ្នាក់ស្រុក និងថ្នាក់រដ្ឋ ដើម្បីអនុវត្តគម្រោងវិស័យសង្គម និងបម្រើការងារនៅក្នុងក្រុមការងារប្រឹក្សាយោបល់គោលនយោបាយ នៃវង់តន្ត្រីរបស់រដ្ឋមន្ត្រីហិរញ្ញវត្ថុឥណ្ឌា ព្រមទាំងបានចូលរួមក្នុងការសម្តែងរបស់ Der Rosenkavalier នៅឯ ENO។

**Judge Ulrike Willoughby**
*ប្រធានអង្គចៅក្រម*
*សាលាឧទ្ធរណ៍ នៅឯ Frankfurt/Main ប្រទេសអាល្លឺម៉ង់*

ចៅក្រម Ulrike Willoughby គឺជាប្រធានអង្គចៅក្រមនៃសាលាឧទ្ធរណ៍ Frankfurt/Main ប្រទេសអាល្លឺម៉ង់។

លោកស្រីបានចាប់ផ្តើមអាជីពផ្នែកច្បាប់របស់លោកស្រី ក្នុងនាមជាអ្នកអនុវត្តច្បាប់ពន្ធដារអន្តរជាតិ ជាមួយ Cleary, Gottlieb, Steen & Hamilton នៅ Frankfurt/Main។ ក្រោយមកលោកស្រីបានចូលបម្រើការងារជាចៅក្រមនៅតុលាការប្រចាំតំបន់ Frankfurt/Main។ លោកស្រីគឺជាប្រធានអង្គចៅក្រមនៃតុលាការប្រចាំតំបន់ Frankfurt/សភាពាណិជ្ជកម្ម អស់រយៈពេលប្រាំបីឆ្នាំ ហើយស្របពេលជាមួយគ្នានេះ លោកស្រីក៏ជាប្រធានចៅក្រមនៃតុលាការប្រចាំតំបន់ Frankfurt/Main សភាពាណិជ្ជកម្មអន្តរជាតិ អស់រយៈពេលបួនឆ្នាំផងដែរ។ បន្ទាប់មកលោកស្រីបានក្លាយជាប្រធានចៅក្រមនៃតុលាការប្រចាំតំបន់ Frankfurt/Main ចាប់ពីឆ្នាំ២០២០-២០២១ និងជាចៅក្រមនៃសាលាឧទ្ធរណ៍ Frankfurt/Main នៅដើមឆ្នាំនេះ មុនពេលដែលនាងបានទទួលតំណែងបច្ចុប្បន្នជាប្រធានចៅក្រមនៃសាលាឧទ្ធរណ៍ Frankfurt/Main ប្រទេសអាល្លឺម៉ង់។ ព្រឹទ្ធសភាដែលលោកស្រីកំពុងបម្រើការងារជាប្រធាន ធ្វើការសម្រេចចិត្តចំពោះបណ្តឹងឧទ្ធរណ៍លើសាលក្រម និងការសម្រេចចិត្តដទៃទៀតរបស់សភាពាណិជ្ជកម្មនៃតុលាការក្នុងតំបន់ចំនួន ៥ ខុសៗគ្នា នៅរដ្ឋ Hesse។